ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ធ៧-០៨-១៩៣ ប្រក

# ប្រកាស
## ស្តីពី
## ការកំណត់ជាថ្មីនូវដើមទុនចុះបញ្ជី និង លក្ខខណ្ឌសុំអាជ្ញាប័ណ្ណ ចំពោះគ្រឹះស្ថានធនាគារ

## ទេសាភិបាលធនាគារជាតិនៃកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១៩៩/១៣ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០៨/៥២៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ស្តីពីការតែងតាំង **ឯកឧត្តម ជា ចាន់តូ** ជាអគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា មានឋានៈស្មើ ទេសរដ្ឋមន្ត្រី
- បានឃើញប្រកាសលេខ ធ៧-០០-០៤ ប្រក ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០០ ស្តីពីការផ្តល់អាជ្ញាប័ណ្ណចំពោះធនាគារពាណិជ្ជ
- បានឃើញប្រកាសលេខ ធ៧-០០-០៥ ប្រក ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០០០ ស្តីពីការផ្តល់អាជ្ញាប័ណ្ណចំពោះធនាគារឯកទេសឥណទានជនបទ
- បានឃើញប្រកាសលេខ ធ៧-០០-៣៩ ប្រក ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០០០ ស្តីពីដើមទុនអប្បបរមារបស់ធនាគារពាណិជ្ជ
- យោងតាមស្មារតីនៃអង្គប្រជុំថ្នាក់ដឹកនាំធនាគារជាតិនៃកម្ពុជា ថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០០៨

## ស ម្រេ ច

**ប្រការ ១.-**

ប្រកាសនេះមានគោលបំណងកំណត់ជាថ្មីនូវដើមទុនចុះបញ្ជីអប្បបរមា និងលក្ខខណ្ឌសុំអាជ្ញាប័ណ្ណ



ប្រអប់សំបុត្រលេខ ២៥, ឡូត៍លេខ ២២-២៤ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ, ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ . ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

ចំពោះគ្រឹះស្ថានធនាគារ។ ធនាគារជាតិនៃកម្ពុជានឹងសិក្សាពីសមត្ថភាពធ្វើប្រតិបត្តិការរបស់បុគ្គលស្នើសុំ ដើម្បីសម្រេចគោលដៅអភិវឌ្ឍន៍របស់ខ្លួន ដោយធ្វើយ៉ាងណាឱ្យបានស្របតាមការងារដ៏រលូននៃប្រព័ន្ធធនាគារ ដើម្បីផ្តល់សុវត្ថិភាពគ្រប់គ្រាន់សម្រាប់សាធារណជន។ ពាក្យស្នើសុំអាជ្ញាប័ណ្ណធ្វើប្រតិបត្តិការធនាគារ ដែលមិនត្រឹមត្រូវតាមលក្ខខណ្ឌដែលមានចែងនៅក្នុងប្រកាសនេះ នឹងត្រូវបដិសេធជាលាយលក្ខអក្សរ។

**ប្រការ ២.-**

គ្រឹះស្ថានធនាគារត្រូវគ្រប់គ្រងដោយបុគ្គលយ៉ាងតិចចំនួនពីររូប ដែលមានភាពសុចរិត និងគុណវុឌ្ឍិ និងមានបទពិសោធន៍សមស្របលើប្រតិបត្តិការធនាគារ។

**ប្រការ ៣.-**

ភាគទុនិកមួយ ឬច្រើន ត្រូវមានភស្តុតាងបង្ហាញថាមានបទពិសោធន៍ក្នុងសកម្មភាពដែលគ្រឹះស្ថានធនាគារមានបំណងធ្វើប្រតិបត្តិការ។

**ប្រការ ៤.-**

គ្រឹះស្ថានធនាគារដែលនឹងត្រូវបង្កើតឡើង ត្រូវមានបុគ្គលិកគ្រប់គ្រាន់ និងមានជំនាញសមស្រប។ ធនធានបច្ចេកទេសរួមទាំងប្រព័ន្ធព័ត៌មាន ត្រូវមានប្រសិទ្ធភាព និងអាចជឿជាក់បានជាពិសេស ប្រព័ន្ធសុវត្ថិភាពនៃប្រតិបត្តិការជាមួយសាធារណជន។

**ប្រការ ៥.-**

គ្រឹះស្ថានធនាគារដែលនឹងត្រូវបង្កើតឡើង ត្រូវបង្កើតប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ដែលអាចឱ្យគ្រឹះស្ថានធនាគារ :

- ធានាបានថាប្រតិបត្តិការ រចនាសម្ព័ន្ធចាត់តាំង នីតិវិធី ប្រតិបត្តិតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន និងការអនុវត្តធុរកិច្ច និងស្តង់ដារជាទូទៅ
- ធានាការប្រតិបត្តិតាមកម្រិតកំណត់ដែលបានដាក់ចេញចំពោះហានិភ័យ ជាពិសេស ហានិភ័យសមភាគី ហានិភ័យអត្រាការប្រាក់ និងហានិភ័យអត្រាប្តូរប្រាក់
- ធានាគុណភាពរបាយការណ៍គណនេយ្យ និងហិរញ្ញវត្ថុ។

**ប្រការ ៦.-**

ភាពឋិតថេរផ្នែកហិរញ្ញវត្ថុរបស់គ្រឹះស្ថានធនាគារក្នុងរយៈពេលច្រើនឆ្នាំខាងមុខ ត្រូវបង្កើតឱ្យបានគ្រប់គ្រាន់តាមរយៈផែនការអាជីវកម្ម ការសិក្សាទីផ្សារ និងការសាកល្បងហិរញ្ញវត្ថុ (financial simulations) រួមទាំង ការធ្វើសេណារីយ៉ូសាកល្បង (stress scenarios) បើចាំបាច់។ ការសាក

ល្បងហិរញ្ញវត្ថុត្រូវមានសូចនាករ ដែលទទួលស្គាល់ជាទូទៅប្រើប្រាស់ក្នុងការវិភាគហិរញ្ញវត្ថុ និងបទដ្ឋានប្រុងប្រយ័ត្ន។

**ប្រការ ៧.-**

មាត្រា ១ នៃប្រកាសលេខ ធ៧-០០-៣៩ ប្រក ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០០០ ស្តីពីដើមទុនអប្បបរមារបស់ធនាគារពាណិជ្ជ ត្រូវជំនួសដោយប្រការដូចខាងក្រោម :

"ធនាគារពាណិជ្ជបង្កើតឡើងក្រោមរូបភាពជាក្រុមហ៊ុន ដែលមានភាគទុនិកមានឥទ្ធិពលយ៉ាងតិចមួយជាគ្រឹះស្ថានធនាគារ ឬ ជាគ្រឹះស្ថានហិរញ្ញវត្ថុដែលមានការវាយតម្លៃ "ចំណាត់ថ្នាក់វិនិយោគ" ដោយភ្នាក់ងារចាត់ថ្នាក់ឯករាជ្យអន្តរជាតិ ត្រូវមានដើមទុនអប្បបរមាស្មើនឹង ៥០.០០០.០០០.០០០ រៀល (ហាសិបពាន់លានរៀល)។ ចំពោះធនាគារពាណិជ្ជដែលមានភាគទុនិកជាវិនិយោគិនដែលជាឯកត្តជន ឬ ក្រុមហ៊ុន ត្រូវមានដើមទុនអប្បបរមាស្មើនឹង ១៥០.០០០.០០០.០០០ រៀល (មួយរយហាសិបពាន់លានរៀល)។"

**ប្រការ ៨.-**

មាត្រា ៤ នៃប្រកាសលេខ ធ៧-០០-០៥ ប្រក ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០០០ ស្តីពីការផ្តល់អាជ្ញាប័ណ្ណចំពោះធនាគារឯកទេសឥណទានជនបទ ត្រូវជំនួសដោយប្រការដូចខាងក្រោម :

"ធនាគារឯកទេសបង្កើតឡើងក្រោមរូបភាពជាក្រុមហ៊ុន ដែលមានភាគទុនិកមានឥទ្ធិពលយ៉ាងតិចមួយជាគ្រឹះស្ថានធនាគារ ឬ ជាគ្រឹះស្ថានហិរញ្ញវត្ថុដែលមានការវាយតម្លៃ "ចំណាត់ថ្នាក់វិនិយោគ" ដោយភ្នាក់ងារចាត់ថ្នាក់ឯករាជ្យអន្តរជាតិ ត្រូវមានដើមទុនអប្បបរមាស្មើនឹង ១០.០០០.០០០.០០០ រៀល (ដប់ពាន់លានរៀល)។ ចំពោះធនាគារឯកទេសដែលមានភាគទុនិកជាវិនិយោគិនដែលជាឯកត្តជន ឬ ក្រុមហ៊ុន ត្រូវមានដើមទុនអប្បបរមាស្មើនឹង ៣០.០០០.០០០.០០០ រៀល (សាមសិបពាន់លានរៀល)។"

**ប្រការ ៩.-**

នីតិវិធី និងការវាយតម្លៃបន្ថែមលើពាក្យស្នើសុំអាជ្ញាប័ណ្ណរបស់គ្រឹះស្ថានធនាគារ ត្រូវបានកំណត់ដោយសារាចរណែនាំដោយឡែក។

**ប្រការ ១០.-**

គ្រឹះស្ថានធនាគារដែលមានអាជ្ញាប័ណ្ណ ឬ ទទួលលិខិតអនុញ្ញាតជាគោលការណ៍បើកធនាគារមុនថ្ងៃប្រកាសនេះចូលជាធរមាន ត្រូវបំពេញដើមទុនឱ្យបានគ្រប់តាមកម្រិតដើមទុនអប្បបរមាដូចមានចែងក្នុងប្រការ ៧ និងប្រការ ៨ នៃប្រកាសនេះ យ៉ាងយឺតបំផុតត្រឹមដំណាច់ឆ្នាំ២០១០។

**ប្រការ ១១.-**

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គាធិការដ្ឋាន អគ្គបេឡា គ្រប់នាយកដ្ឋាន និងអង្គភាពក្រោមឱវាទធនាគារជាតិនៃកម្ពុជា និងគ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ នៅក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ។

**ប្រការ ១២.-**

ប្រកាសនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៨

**ទេសាភិបាល**

**ជា-ចាន់តូ**

**<u>កន្លែងទទួល</u>**

- ដូចប្រការ ១១ "ដើម្បីអនុវត្ត"
- កាលប្បវត្តិ
- ឯកសារ

**<u>ចម្លងជូន</u>**

- សមាជិកក្រុមប្រឹក្សាភិបាល
- ទីស្តីការគណៈរដ្ឋមន្ត្រី
  "ដើម្បីជ្រាបជាព័ត៌មាន"
- នាយកដ្ឋានរដ្ឋបាលនៃទីស្តីការគណៈរដ្ឋមន្ត្រី
  "ដើម្បីចុះផ្សាយក្នុងរាជកិច្ច"